# សព្វានុក្រម

| ភាសាបរទេស English | ភាសាខ្មែរ Khmer | កំណត់សម្គាល់ Note |
|---|---|---|
| Constitution | លក្ខន្តិកៈ | |
| Members | សមាជិក និងសមាជិកា | |
| Comittee | គណៈកម្មការ | |
| President | ប្រធាន | |
| Vice-President | អនុប្រធាន | |
| Secteary | លេខាធិការ | |
| Teasurer | ហេរញ្ញិក | |
| Ordinary Member | សមាជិកធម្មតា | |
| Management Committee | គណៈកម្មការប្រតិបត្តិ | |
| Annual General Meeting | អង្គសន្និបាតប្រចាំឆ្នាំ | |
| Office Bearer | តួនាទីជាថ្នាក់ដឹកនាំ | |
| General Meeting | ប្រជុំសាមញ្ញ | |
| Management | ការគ្រប់គ្រង | |
| Office | តួនាទី | e.g. cease to hold such office |
| Sub-Committee | អនុគណៈកម្មការ | |
| Office of Consumer Affairs | ការិយាល័យកិច្ចការអតិថិជន | |
| Casting Vote | បោះឆ្នោតបញ្ចប់ការជាប់គាំង | |
| Deliberative Vote | បោះឆ្នោតជាលើកទីពីរ (២) | |
| Associations Incorporation Act | ច្បាប់សមាគមសាជីវកម្ម | |
| Trustee securities | មូលបត្ររបស់ក្រុមប្រឹក្សាភិបាល | |
| audit | សវនកម្ម | |
| Speical General Meeting | អង្គប្រជុំពិសេស | |
| Ordinary Committee Members | សមាជិក សមាជិកាគណៈកម្មការសាមញ្ញ | |
| Good character | ចរិតលក្ខណៈសម្បត្តិ | |
| Absentee voting | បោះឆ្នោតតាងនាម | |
| Postial vote | បោះឆ្នោតតាមវិធីផ្ញើសំបុត្រ | |
| Petty cash | ចាយជាក្រដាសប្រាក់ | |
| | | |
| | | |

# លក្ខន្តិកៈ
# សមាគមខ្មែរសាជីវកម្មរដ្ឋអូស្ត្រាលីខាងត្បូង

## មាត្រា ១ - ឈ្មោះ

ឈ្មោះរបស់សមាគមគឺ **សមាគមខ្មែរសាជីវកម្មរដ្ឋអូស្ត្រាលីខាងត្បូង** ដែលចាប់ពីកថានេះតទៅ ហៅថា "សមាគម"

## មាត្រា ២ - គោលបំណង

គោលបំណងរបស់សមាគមមានចែងដូចតទៅ៖

2.1 ផ្តល់សេវាកម្មដល់សមាជិក និងសមាជិកាសមាគម ផ្នែកសុខុមាលភាព គាំទ្រដល់ការសម្របខ្លួនចូលក្នុងសង្គម ការការពារ និងសេវាកម្មសង្គមផ្សេងៗទៀត ជាពិសេសណែនាំក្នុងការទទួលសេវាកម្មនៃក្រសួង និងអង្គការដែលពាក់ព័ន្ធនានា។

2.2 ថែរក្សា ផ្សព្វផ្សាយ និងអភិវឌ្ឍន៍នូវទំនៀមទំលាប់ ប្រពៃណី កេរ្តិ៍ដំណែល សាសនា និងភាសាខ្មែរ រួមទាំងបង្កើតសុច្ឆន្ទៈព្រមទាំងមិត្តភាពរវាងប្រជាពលរដ្ឋខ្មែរ និងសង្គមអូស្ត្រាលីទាំងមូល។

2.3 ធ្វើគ្រប់កិច្ចការផ្សេងៗទៀតដែលស្របទៅតាមគោលបំណងខាងលើ ហើយត្រូវប្រាកដថា កិច្ចការទាំងនោះត្រូវទទួលធ្វើដោយសមស្របតាមបែបបទសង្គម និងក្នុងលក្ខណៈទទួលខុសត្រូវខ្ពស់។

## មាត្រា ៣ - សមាជិកភាព

3.1 សមាជិក និងសមាជិកាសមាគម ជាបុគ្គលដែល៖

a) គាំទ្រនូវគោលបំណងខាងលើ;

b) បានបំពេញលិខិតចូលជាសមាជិក;

c) បានបង់ថ្លៃសមាជិកភាព និង;

d) ទទួលឱ្យចូលជាសមាជិកដោយការបោះឆ្នោតជាមតិភាគច្រើននៃគណៈកម្មការ។

3.2 លេខាធិការរបស់សមាគមត្រូវតែទទួលធ្វើជាបន្ទាន់តាមដែលអាចធ្វើបាន បន្ទាប់ពីគណៈកម្មការប្រតិបត្តិបានយល់ព្រម ឬ បដិសេធការដាក់ពាក្យសុំចូលជាសមាជិក, ដោយធ្វើជូនអ្នកដាក់ពាក្យសុំចូលជាសមាជិកជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តនោះ។ ប្រសិនជាការដាក់ពាក្យសុំចូលជាសមាជិកបានត្រូវទទួលយល់ព្រម បណ្ណសមាជិកនឹងត្រូវធ្វើជូនទៅឱ្យសមាជិក ឬ សមាជិកាដែលបានដាក់ពាក្យនោះ។

3.3 ការដាក់ពាក្យសុំចូលជាសមាជិកនឹងត្រូវបិទចំនួនមួយ (១) ខែមុនពេលអង្គសន្និបាតប្រចាំឆ្នាំដែលនឹងត្រូវធ្វើឡើងសម្រាប់ការបោះឆ្នោតជ្រើសរើសតួនាទីជាថ្នាក់ដឹកនាំ។ សមាជិក និងសមាជិកាទាំងឡាយណាដែលដាក់ពាក្យចូលជាសមាជិកភាពនឹងមិនមានសិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសតួនាទីជាថ្នាក់ដឹកនាំឡើយ។

## មាត្រា ៤ - ការចុះឈ្មោះចូលជាសមាជិក

4.1 លេខាធិការត្រូវតែរក្សាបញ្ជីក្នុងការចុះឈ្មោះរបស់សមាជិក និងសមាជិការបស់សមាគមដោយមាន៖

a. គោត្តនាម និងនាមខ្លួនរបស់សមាជិក និងសមាជិកា;

b. អាសយដ្ឋានរស់នៅ ឬ អាសយដ្ឋានប្រៃសណីយ៍ និងអ៊ីម៉ែលរបស់សមាជិក និងសមាជិកា;

c. ថ្ងៃចុះឈ្មោះចូលជាសមាជិក;

d. ប្រសិនជាអាច ត្រូវចុះថ្ងៃដែលសមាជិក ឬ សមាជិការូបណាមួយសុំលាលែង និង;
e. មូលហេតុដែលសមាជិក ឬ សមាជិការូបនៅសុំលាលែងពីសមាជិកភាព។

4.2 បញ្ជីឈ្មោះដែលមានរៀបរាប់ខាងលើ ត្រូវបានរក្សាទុកសម្រាប់ឱ្យសមាជិក និងសមាជិកាពិនិត្យមើលដោយមិនគិតថ្លៃប្រសិនជាមានការស្នើសុំ។

4.3 សមាជិក និងសមាជិការបស់សមាគម មិនត្រូវយកព័ត៌មានទាំងឡាយណាដែលបានមកពីបញ្ជីឈ្មោះខាងលើដើម្បីទាក់ទង ឬ ផ្ញើសម្ភារៈនានាទៅកាន់សមាជិក ឬ សមាជិកាណាមួយរបស់សមាគមក្នុងគោលបំណងផ្សព្វផ្សាយដំណឹងសម្រាប់ជាផលប្រយោជន៍នយោបាយ, សាសនា, អង្គការសប្បុរសធម៌ ឬ ក្នុងគោលបំណងផ្សាយពាណិជកម្ម ឬ ផ្តល់ដំណឹងទៅឱ្យបុគ្គលណាម្នាក់ទៀតឡើយ, ទោះបីជាដឹងថាបញ្ជីឈ្មោះខាងលើអាចនឹងយកទៅប្រើក្នុងគោលបំណងនោះក៏ដោយ។

4.4 មាត្រា 4.3 អាចនឹងលើកលែងបាន ប្រសិនជាសមាគមអនុញ្ញាតឱ្យប្រើ ឬ អនុញ្ញាតឱ្យលាតត្រដាងព័ត៌មានទាំងនោះ។

## មាត្រា ៥ - ការសុំលាលែងពីសមាជិកភាព

5.1 សមាជិក និងសមាជិកាម្នាក់ អាចសុំលាលែងពីសមាជិកភាពនៃសមាគមបាន ដោយការផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរនៃការសុំលាលែងនោះឱ្យទៅលេខាធិការ។

5.2 ការសុំលាលែងនឹងមានប្រសិទ្ធភាពនៅពេលដែលលេខាធិការបានទទួលសំបុត្រសុំលាលែងខាងលើ។

5.3 គណៈកម្មការប្រតិបត្តិ ដោយធ្វើការបោះឆ្នោតយកមតិភាគច្រើនពីរភាគបី (២/៣) នឹងមានសិទ្ធិសម្រេចដកសមាជិកភាពរបស់សមាជិក និងសមាជិកាណាមួយប្រសិនជាសមាជិករូបនោះ៖

a. ប្រព្រឹត្តបទឧក្រិដ្ឋ ឬ
b. មិនបានអនុវត្តតាមបទបញ្ជាដែលបានចែងក្នុងលក្ខន្តិកៈរបស់សមាគមខាងលើ ឬ
c. មិនបានបង់ថ្លៃសមាជិកបន្តចំនួនយ៉ាងហោចណាស់បី (៣) ខែ ឬ
d. ប្រព្រឹត្តអំពើដែលបុគ្គលនោះនឹងធ្វើឱ្យខូចផលប្រយោជន៍ កេរ្តិ៍ឈ្មោះ និងជំហររបស់សមាគម។

5.4 មុននឹងគណៈកម្មការប្រតិបត្តិបញ្ឈប់សមាជិក សមាជិកាណាមួយ គណៈកម្មការត្រូវផ្តល់ហេតុផលឱ្យបានពេញលេញ និងយុត្តិធម៌ពីមូលហេតុនៃការបញ្ឈប់នោះ។ បុគ្គលនោះក៏មានសិទ្ធិក្នុងការតវ៉ា ហេតុអ្វីបានជាសមាគមមិនមានសិទ្ធិដកហូតនូវសមាជិកភាពរបស់ខ្លួន។

5.5 ប្រសិនបើបន្ទាប់ពីការតវ៉ា និងពិចារណាគ្រប់ជ្រុងជ្រោយហើយ គណៈកម្មការប្រតិបត្តិសម្រេចដកនូវសមាជិកភាព លេខាធិការត្រូវសរសេរសំបុត្រជាផ្លូវការ ដើម្បីជូនដំណឹងដល់ សមាជិក និងសមាជិការូបនោះជាលាយលក្ខណ៍អក្សរ អំពីការសម្រេចចិត្តរបស់គណៈកម្មការ។

## មាត្រា ៦ - បណ្តឹងឧទ្ធរណ៍ចំពោះការដកសមាជិកភាព ឬ ការបដិសេធនៃការក្លាយជាសមាជិកភាពរបស់សមាគម

6.1 បុគ្គលណាដែលបានដាក់ពាក្យសុំជាសមាជិក ឬ សមាជិកានៃសមាគម ហើយត្រូវបានបដិសេធ ឬ សមាជិកភាពត្រូវបានដក សមាជិក ឬ សមាជិការូបនោះអាចសរសេរសំបុត្រជាផ្លូវការមកលេខាធិការ ដើម្បីប្តឹងតវ៉ានៃសេចក្តីសម្រេចនោះ។

6.2 បណ្តឹងឧទ្ធរណ៍នេះត្រូវបញ្ជូនមកដល់លេខាធិការក្នុងកំឡុងពេលមួយ (១) ខែជាកំហិតក្រោយពីបុគ្គលនោះទទួលបាននូវសេចក្តីសម្រេចដូចខាងលើ។

6.3 នៅពេលដែលលេខាធិការបានទទួលនូវបណ្តឹងឧទ្ធរណ៍នេះ លេខាធិការត្រូវកោះហៅអង្គប្រជុំសាមញ្ញ ក្នុងរយៈពេលមួយ (១) ខែជាកំហិតដើម្បីដោះស្រាយការតវ៉ានោះជាផ្លូវការ។

6.4 ការប្រជុំសាមញ្ញដើម្បីសម្រេចពីបណ្តឹងឧទ្ធរណ៍នឹងត្រូវសម្រេចជាលទ្ធផលក្នុងកំឡុងពេលបី (៣) ខែជាកំហិតក្រោយពីពេលលេខាធិការទទួលបាននូវបណ្តឹងឧទ្ធរណ៍នោះ។

6.5 នៅក្នុងពេលប្រជុំនោះ បុគ្គលដែលត្រូវបានរំសាយសមាជិកភាពអាចអនុញ្ញាតឱ្យមានការនិយាយដោយពេញលេញ និងយុត្តិធម៌ក្នុងគោលបំណងតវ៉ារកមូលហេតុអ្វីដែលសមាគមមិនគួរបញ្ឈប់ ឬ បដិសេធសមាជិកភាព។

6.6 ដូចគ្នានេះផងដែរ សមាជិក និងសមាជិកានៃគណៈកម្មការប្រតិបត្តិរបស់សមាគម និងសមាជិកគណៈកម្មការរបស់សមាគម នឹងត្រូវផ្តល់សិទ្ធិអនុញ្ញាតឱ្យមានការនិយាយដោយពេញលេញ និងយុត្តិធម៌ក្នុងគោលបំណងបង្ហាញពីមូលហេតុដែលសមាគមគួរបញ្ឈប់ ឬ មិនបដិសេធនៃការដកសមាជិកភាពនៃបុគ្គលរូបនោះ។

6.7 បណ្តឹងឧទ្ធរណ៍នេះត្រូវតែសម្រេចដោយការបោះឆ្នោតជាមតិភាគច្រើននៅពេលដែលសមាជិក និងសមាជិការបស់សមាគមកំពុងចូលរួមនៃការប្រជុំ និងមានសិទ្ធិពេញលេញក្នុងការបោះឆ្នោតក្នុងអង្គប្រជុំ។

6.8 បុគ្គលណាដែលបានដាក់ពាក្យជាសមាជិក និងសមាជិកានៃសមាគម ហើយការដាក់ពាក្យនោះត្រូវបានបដិសេធ និងច្រានចោល ហើយបុគ្គលនោះមិនបានដាក់បណ្តឹងបដិសេធនៃការសម្រេចចិត្តក្នុងរយៈពេលមួយ (១) ខែ បណ្តឹងឧទ្ធរណ៍របស់បុគ្គលនោះនឹងត្រូវចាត់ទុកជាអសារបង់ ហើយលេខាធិការត្រូវផ្តល់ជូនថវិកានៃសមាជិកភាពដល់បុគ្គលនោះវិញ។

## មាត្រា ៧ - ការគ្រប់គ្រង

7.1 ការគ្រប់គ្រងនៃគណៈកម្មការត្រូវមានសុពលភាពត្រឹមតែមួយអាណត្តិ ដែលកាន់តំណែងបានតែពីរ (២) ឆ្នាំប៉ុណ្ណោះ ចាប់តាំងពីអង្គសន្និបាតប្រចាំឆ្នាំ ដែលបានចែងក្នុងមាត្រាដប់ (១០)។

7.2 សមាសភាពនៃគណៈកម្មការរួមមាន ប្រធាន អនុប្រធាន លេខាធិការ ហេរញ្ញិក (តួនាទីជាថ្នាក់ដឹកនាំ) និងសមាជិកធម្មតាប្រាំមួយ (៦) នាក់។

7.3 គណៈកម្មការត្រូវជួបប្រជុំឱ្យបានច្រើនតាមអ្វីដែលអាចធ្វើបាន ដើម្បីឱ្យសមាគមមានដំណើរការ និងមិនត្រូវតិចជាងបួន (៤) ដងក្នុងមួយឆ្នាំ។

7.4 ការប្រជុំនានាត្រូវមានសមាសភាពបួន (៤) នាក់ យ៉ាងតិចណាស់ពីរ (២) នាក់មានតួនាទីជាថ្នាក់ដឹកនាំ។

7.5 ប្រធាន ឬ សមាជិកពីរ (២) រូបនៃគណៈកម្មការ មានសិទ្ធិកោះហៅអង្គប្រជុំ នៃគណៈកម្មការបាន។

7.6 ការកំណត់ពេលវេលានៃរាល់អង្គប្រជុំ ត្រូវឱ្យដំណឹងក្រោយនៅពេលបញ្ចប់ពីការប្រជុំហើយម្តងៗ ឬ មុនប្រាំពីរ (៧) ថ្ងៃដោយជាលាយលក្ខណ៍អក្សរទៅដល់រាល់សមាជិក និងសមាជិកានៃគណៈកម្មការប្រតិបត្តិ ឬក្នុងពេលបន្ទាន់ការសម្រេចដទៃទៀតគឺអាស្រ័យទៅលើគណៈកម្មការប្រតិបត្តិដែលកំពុងកាន់ដំណែង។

7.7 ថ្នាក់ដឹកនាំនៃសមាគម ឬ សមាជិក និងសមាជិកានៃគណៈកម្មការប្រតិបត្តិត្រូវអស់តួនាទីនៅពេល៖

- 7.7.1 ត្រូវបានលាលែងពីតំណែងជាផ្លូវការ ដោយលាយលក្ខណ៍អក្សរ;
- 7.7.2 ត្រូវបានដកសមាជិកភាពពីសមាគមជាបណ្តោះអាសន្ន;
- 7.7.3 ខកខានមិនបានមកប្រជុំចំនួនបី (៣) លើកផ្ទួនៗដោយគ្មានហេតុផល និងមិនអាចទទួលបាន
- 7.7.4 ការបោះឆ្នោតដោយមតិភាពច្រើនរបស់សមាជិក និងសមាជិការបស់សមាគម នៅការប្រជុំសាមញ្ញមួយ ដោយតំណែងនោះត្រូវបានប្រកាសទំនេរជាផ្លូវការ ដោយហេតុតួនាទី

នោះមិនបានធ្វើត្រឹមត្រូវ និងមិនអាចទទួលយកបាន ដោយផ្តល់ថាតំណែងទំនេរនោះនឹងត្រូវផ្តល់ដំណឹងជូនគ្រប់សមាជិក និងសមាជិកានៃសមាគម។ ហើយបុគ្គលដែលត្រូវបានដកពីតំណែងនោះ ត្រូវមានឱកាសបកស្រាយពីហេតុផលនាពេលអង្គប្រជុំសាមញ្ញនោះ។

7.8 គណៈកម្មការអាចនៅដំណើរការដដែលទោះបីជាមានតំណែងទំនេរណាមួយក៏ដោយ ឱ្យតែសមាសភាពគណៈកម្មការមិនក្រោមចំនួនកំណត់នៃលក្ខន្តិកៈរបស់សមាគម។

7.9 គណៈកម្មការអាចមានសិទ្ធិជ្រើសតាំងបុគ្គលណាម្នាក់ដើម្បីកាន់តំណែងទំនេរណាមួយជាបណ្តោះអាសន្នរហូតដល់អង្គសន្និបាតប្រចាំឆ្នាំរបស់សមាគម ហើយបុគ្គលរូបនោះត្រូវមានសិទ្ធិឈរឈ្មោះជាស្វ័យប្រវត្តិក្នុងការបោះឆ្នោតនៃគណៈកម្មការ។

7.10 គណៈកម្មការអាចជ្រើសតាំងអនុគណៈកម្មការនៃសមាគម មកពីសមាជិកភាព និងពីអសមាជិកភាពដើម្បីបំពេញតម្រូវការអ្វីមួយ។ អនុគណៈកម្មការអាចបង្កើតអង្គប្រជុំដោយខ្លួនឯង ឬ ដោយមានការណែនាំពីគណៈកម្មការ និងត្រូវមានបុគ្គលរូបណាមួយតំណាងក្នុងការរាយការណ៍មកគណៈកម្មការវិញអំពីសកម្មភាពរបស់ខ្លួន។

7.11 គណៈកម្មការមានសិទ្ធិក្នុងការសហការជាមួយបុគ្គលដទៃដែលជាជនមានជំនាញ ឬ ចំណេះដឹងពិសេសដើម្បីជួយនូវការសម្រេចអ្វីមួយ ប៉ុន្តែបុគ្គលនោះគ្មានសិទ្ធិក្នុងការបោះឆ្នោតទេ។

7.12 គណៈកម្មការអាចចាត់តាំងថ្នាក់ដឹកនាំណាមួយ ជាមួយនឹងសមាជិក ឬ សមាជិកាណាមួយទៀតក្នុងគណៈកម្មការ ដែលមានតួនាទីបម្រើសេវានានាដែលបានប្រគល់ដោយគណៈកម្មការ។ បុគ្គលនោះត្រូវមានតួនាទីរាយការណ៍មកគណៈកម្មការអំពីសកម្មភាពរបស់ខ្លួន។

7.13 គណៈកម្មការអាចចាត់តាំងថ្នាក់ដឹកនាំណាមួយ ដែលមានតួនាទីប្រាប់ដំណឹងនៃការតែងតាំងនានានៃសមាគម រួមទាំងព័ត៌មាន និងឯកសារផ្លូវច្បាប់នានាទៅការិយាល័យកិច្ចការអតិថិជន (Office of Consumer Affairs)។ បុគ្គលនោះនឹងត្រូវកាន់តំណែងនោះលុះត្រា គណៈកម្មការតែងតាំងអ្នកថ្មីឱ្យមកជំនួស។

7.14 សមាជិក និងសមាជិកាគណៈកម្មការអាចបញ្ចេញទស្សនៈវិស័យ ឬ ចំណាប់អារម្មណ៍ទៅលើអង្គការ ឬ ក្រុមណាដែលខ្លួនតំណាង ប៉ុន្តែនៅពេលការបោះឆ្នោតក្នុងសមាគម បុគ្គលនោះនឹងបោះឆ្នោតយោងតាម និងដើម្បីជាផលប្រយោជន៍ស្រមទៅតាមគោលការណ៍របស់សមាគម។

7.15 សមាជិក និងសមាជិកាគណៈកម្មការ មិនត្រូវបោះឆ្នោតទៅលើសេចក្តីសម្រេចណាមួយ ក្នុងករណីដែលគេ, សមាជិកគ្រួសារជិត ឬ ឆ្ងាយរបស់គេ, ឬ សហការីណាមួយដែលមានការទាក់ទងនឹងផ្នែកហិរញ្ញវត្ថុរបស់គេ។ សមាជិក និងសមាជិកាគណៈកម្មការនោះមិនត្រូវប្រើតួនាទីរបស់ខ្លួនដើម្បីទាញយកផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬ ផលប្រយោជន៍ផ្ទាល់ខ្លួន, ផលប្រយោជន៍សម្រាប់គ្រួសារជិត ឬ ឆ្ងាយ ឬ សហការីណាមួយឡើយ។

7.16 សំនួរដែលលើកឡើងក្នុងអង្គប្រជុំរបស់គណៈកម្មការត្រូវសម្រេចដោយមតិភាគច្រើន ហើយក្នុងករណីដែលមានមតិស្មើគ្នា ប្រធានអង្គប្រជុំមានសិទ្ធិបោះឆ្នោតបញ្ចប់ការជាប់គាំង រួមជាមួយទាំងសិទ្ធិក្នុងការបោះឆ្នោតជាលើកទីពីរ (២)។

## មាត្រា ៨ - អំណាច

8.1 អំណាចរបស់សមាគម គឺជាអំណាចដែលស្ថិតនៅក្រោមក្រិតក្រមនៃច្បាប់ **សមាគមសាជីវកម្ម** (Associations Incorporation Act) និងកម្រិតនៃអំណាចច្បាប់នេះអាចអនុញ្ញាតឱ្យសមាគមមានលទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិពិតប្រាកដ ឬ ទ្រព្យសម្បត្តិឯកជន, បើក និងប្រើប្រាស់គណនេយ្យធនាគារ, ធ្វើវិនិយោគក្នុងមូលបត្ររបស់ក្រុមប្រឹក្សាភិបាល, និងមានសិទ្ធិធ្វើ និងចុះកិច្ចសន្យានានា រាប់បញ្ចូលទាំងកិច្ចសន្យាជួលបុគ្គលិកផងដែរ។

8.2 គណៈកម្មការមានសិទ្ធិពេញលេញក្នុងការអនុវត្តអំណាចរបស់ខ្លួន ដោយអំណាចនោះរួមទាំងការចាត់ចែង និងគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានារបស់សមាគម, គណៈកម្មការក៏មានសិទ្ធិខ្ចីលុយនានា លុំកណាតែបានសេចក្តីយល់ព្រមពីអង្គប្រជុំសាមញ្ញ, យកទ្រព្យសម្បត្តិសមាគមទៅដាក់ធានាក្នុងការខ្ចីលុយ ឬ ប្រាក់ចំណូលដែលបានមកពីអត្ថប្រយោជន៍ផ្សេងៗ ដែលមានតម្លៃប្រាំពាន់ដុល្លារ ($៥០០០) ឡើង។

## មាត្រា ៩ - អង្គប្រជុំសាមញ្ញ

9.1 សន្និបាតប្រចាំឆ្នាំត្រូវប្រារព្ធឡើងយ៉ាងហោចណាស់មួយ (១) ឆ្នាំម្តង ហើយមិនឱ្យហួសពីប្រាំ (៥) ខែ បន្ទាប់ពីការធ្វើថវិកាដំណាច់ប្រចាំឆ្នាំ។

9.2 របៀបវារៈនៃសន្និបាតប្រចាំឆ្នាំត្រូវតែៈ

9.2.1 ទទួលស្គាល់ពីកំណត់ហេតុនៃសន្និបាតប្រចាំឆ្នាំកន្លងមក;

9.2.2 ទទួលរបាយការណ៍របស់ប្រធានពីសន្និបាតប្រចាំឆ្នាំមុន;

9.2.3 ទទួលរបាយការណ៍របស់ហេរញ្ញិក និងការធ្វើសវនកម្មហិរញ្ញវត្ថុពីសន្និបាតប្រចាំឆ្នាំមុន រួមជាមួយនឹងគម្រោងថវិកាប្រចាំឆ្នាំថ្មីនេះ;

9.2.4 បោះឆ្នោតជ្រើសរើស ឬ ជ្រើសរើសសាជាថ្មីនូវប្រធាន និងអនុប្រធាន, និងសមាជិក សមាជិកាផ្សេងៗទៀតក្នុងរយៈពេលពីរឆ្នាំម្តង;

9.2.5 ធ្វើកិច្ចការផ្សេងៗទៀតដែលមានចែងតាមរបៀបវារៈមុនពេលអង្គប្រជុំចាប់ផ្តើម។

9.3 អង្គប្រជុំពិសេសអាចនឹងត្រូវកោះហៅបានដោយលេខាធិការក្នុងកំឡុងពេលម្ភៃប្រាំបី (២៨) ថ្ងៃក្រោយពីមានការណែនាំពី គណៈកម្មការ, ឬ ការស្នើសុំយ៉ាងតិចណាស់បី (៣) រូបពីសមាជិក ឬ សមាជិកាគណៈកម្មការ, ឬ ការស្នើសុំយ៉ាងតិចណាស់ប្រាំមួយ (៦) រូបពីសមាជិកទូទៅ និងជាលាយលក្ខណ៍អក្សរអំពីគម្រោងនៃរបៀបវារៈរបស់អង្គប្រជុំ។

9.4 សេចក្តីប្រកាសមិនតិចជាងដប់បួន (១៤) ថ្ងៃនៅសន្និបាតប្រចាំឆ្នាំនឹងត្រូវបិទប្រកាសនៅទីស្នាក់ការរបស់សមាគម និង ផ្សព្វផ្សាយដំណឹងដល់សមាជិក និងសមាជិកាទាំងអស់ដែលមិនបានចេញចូលទីស្នាក់ការជាញឹកញាយ។

9.5 សមាជិក ឬ សមាជិកាមួយរូបៗមានសិទ្ធិបោះឆ្នោតបានមួយសម្លេងនៅសន្និបាតប្រចាំឆ្នាំ នៅពេលដែលបុគ្គលនោះកំពុងមានវត្តមាន។

9.6 ការប្រជុំសាមញ្ញនានាត្រូវការចំនួនយ៉ាងតិចណាស់ដប់ (១០) នាក់នៃសមាជិក និងសមាជិកាធម្មតា ឬ ក៏ពីរភាគបី (២/៣) នៃសមាជិកសរុបក្នុងប្រការណាដែលតិចជាងគេ។

9.7 ប្រសិនជាការប្រជុំសាមញ្ញណាដែលគ្មានចំនួនសមាជិក និងសមាជិកក្នុងរយៈពេលសាបសិន (៣០) នាទីនៃការប្រជុំ ការប្រជុំសាមញ្ញនោះត្រូវទុកជាមោឃៈ និងត្រូវលើកទៅកាលបរិច្ឆេទពេលក្រោយតែមិនត្រូវលើសពីម្ភៃប្រាំបី (២៨) ថ្ងៃ។

**មាត្រា ១០ - ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ និងសមាជិក សមាជិកាគណៈកម្មការសាមញ្ញ**

10.1 បេក្ខភាពទាំងអស់ដែលឈរឈ្មោះក្នុងសន្និបាតប្រចាំឆ្នាំត្រូវ ៖

10.1.1 មានដើមកំណើតជាជនជាតិខ្មែរ ប្រសិនបុគ្គលនោះមិនមានដើមកំណើតជាជនជាតិខ្មែរ បុគ្គលនោះអាចឈរឈ្មោះជាសមាជិក សមាជិកាគណៈកម្មការសាមញ្ញដោយស្របទៅនឹងមាត្រា 10.1.2;

10.1.2 បុគ្គលដែលមិនមានដើមកំណើតជាជនជាតិខ្មែរ អាចឈរឈ្មោះជាសមាជិក សមាជិកាគណៈកម្មការសាមញ្ញបាន លុះត្រាតែការជាប់នោះមិនត្រូវលើសពីពីរ (២) នាក់ ឬ ម្ភៃ (២០) ភាគរយនៃគណៈកម្មការទាំងមូល ជ្រើសយកប្រការណាដែលតិចជាង;

10.1.3 យោងទៅតាមមាត្រា **10.9** បុគ្គលនោះត្រូវតែជាសមាជិក ឬ សមាជិកាដែលមានសមាជិកភាពដោយបង់ប្រាក់សមាជិករបស់សមាគមយ៉ាងតិចក្នុងរយៈពេលដប់ពីរ (១២) ខែមុនការឈរឈ្មោះ;

10.1.4 ត្រូវចេះភាសាអង់គ្លេសល្អគ្រប់គ្រាន់ក្នុងការយល់ដឹងនូវឯកសារនានា ដើម្បីបំពេញនូវគោលជំហររបស់សមាគម;

10.1.5 ជាបុគ្គលដែលមានចរិតលក្ខណៈសម្បត្តិល្អ;

10.1.6 មិនមែនជាអ្នកក្ស័យធន ឬ ជាបុគ្គលដែលមិនអាចសងបំណុលគេបាន;

10.1.7 មិនមានជាប់ទោសដែលឈានទៅដល់ការដាក់ពន្ធនាគារ ទោះបីជាត្រូវព្យួរទោសក៏ដោយ។

10.2 បេក្ខភាពមួយរូបៗ អាចឈរឈ្មោះជាថ្នាក់ដឹកនាំ និងជាសមាជិក សមាជិកាគណៈកម្មការសាមញ្ញបាន ប៉ុន្តែអាចកាន់បានតែមួយតំណែងទេ។

10.3 ការជ្រើសរើសបេក្ខជន ឬ បេក្ខនារីឱ្យឈរឈ្មោះសម្រាប់ការបោះឆ្នោតជាប្រធាន ឬ ជាសមាជិក សមាជិកាសាមញ្ញរបស់គណៈកម្មការសាមញ្ញត្រូវតែ៖

a. សរសេរជាលាយលក្ខណ៍អក្សរដោយមានហត្ថលេខារបស់សមាជិក ឬ សមាជិកាដែលបានបង់លុយសមាជិកភាពរបស់សមាគមយ៉ាងហោចណាស់មួយ (១) នាក់ដោយភ្ជាប់ជាមួយលិខិតយល់ព្រមរបស់បេក្ខភាព

b. ផ្ញើទៅកាន់លេខាធិការរបស់សមាគមមិនតិចជាងប្រាំពីរ (៧) ថ្ងៃមុនថ្ងៃសន្និបាតប្រចាំឆ្នាំ

10.4 សមាជិក សមាជិកាគណៈកម្មការបច្ចុប្បន្នអាចឈរឈ្មោះ បោះឆ្នោតសារជាថ្មីដោយមិនបាច់មានការតែងតាំង។

10.5 ប្រសិនជាបេក្ខភាពឈរឈ្មោះមិនមានគ្រប់ចំនួនក្នុងគណៈកម្មការ បេក្ខភាពឈរឈ្មោះទាំងអស់ត្រូវចាត់ទុកជាជាប់ឆ្នោត ហើយការតែងតាំងបេក្ខជន បេក្ខនារីបន្ថែមទៀតអាចធ្វើឡើងនៅក្នុងសន្និបាតប្រចាំឆ្នាំ។

10.6 ប្រសិនជាបេក្ខភាពឈរឈ្មោះមានចំនួនស្មើនឹងចំនួនតំណែងទំនេរក្នុងគណៈកម្មការ បេក្ខភាពទាំងអស់នឹងត្រូវចាត់ទុកជាជាប់ឆ្នោតដោយធរមាន។

10.7 ប្រសិនជាបេក្ខភាពឈរឈ្មោះមានចំនួនលើសពីតំណែងទំនេរ ការបោះឆ្នោតនឹងត្រូវរៀបចំឡើងនៅថ្ងៃសន្និបាតប្រចាំឆ្នាំ យោងទៅតាមមាត្រាដប់មួយ (១១) នៃលក្ខន្តិកៈនេះ។

10.8 ប្រសិនជាគ្មានបេក្ខភាពឈរឈ្មោះក្នុងពេលបោះឆ្នោត គណៈកម្មការបច្ចុប្បន្នមានកាតព្វកិច្ចបន្តការគ្រប់គ្រងសមាគមរហូតដល់គណៈកម្មការថ្មីត្រូវបានជ្រើសរើស។

10.9 ក្រោយពីពេលបោះឆ្នោតភ្លាម និងបន្ទាប់ពីបោះឆ្នោតសម្រេចជាផ្លូវការនូវលក្ខន្តិកៈថ្មី, បេក្ខភាពឈរឈ្មោះសម្រាប់តួនាទីជាសមាជិក ឬ សមាជិកាគណៈកម្មការសាមញ្ញ ត្រូវតែជាបុគ្គលដែលបានបង់ប្រាក់ជាសមាជិកភាពយ៉ាងតិចណាស់បួន (៤) សប្តាហ៍មុននឹងថ្ងៃបោះឆ្នោត។

10.10 នៅថ្ងៃប្រជុំគណៈកម្មការលើកដំបូង ក្រោយពីថ្ងៃបោះឆ្នោតរួច, សមាជិក និងសមាជិកានៃគណៈកម្ម

ការថ្មីនឹងត្រូវធ្វើការបោះឆ្នោតជ្រើសរើសយកអនុប្រធាន ហេរញ្ញិក និងលេខាធិការ ក្នុងចំណោមសមាជិក និងសមាជិកានៃគណៈកម្មការថ្មីនោះ។

**មាត្រា ១១ - ការបោះឆ្នោត**

11.1 ការបោះឆ្នោតរើសតំណែងប្រធាន និងសមាជិក សមាជិកាគណៈកម្មការទាំងអស់នឹងត្រូវធ្វើឡើងដោយបោះឆ្នោតជាសម្ងាត់។

11.2 ការបោះឆ្នោតតាមវិធីផ្ញើសំបុត្រ ឬ បោះឆ្នោតតាងនាម មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែបេក្ខភាពនេះមានជំងឺ ហើយកំពុងសម្រាកក្នុងមន្ទីរពេទ្យ។

**មាត្រា ១២ - ប្រធាន**

12.1 ប្រធានត្រូវរក្សាត្រារបស់សមាគម ហើយអាចប្រើត្រានេះដោយការសម្រេចយល់ព្រមពីគណៈកម្មការសមាគម ឬ ពីការប្រជុំសាមញ្ញ និងត្រូវមានវត្តមានសមាជិក ឬ សមាជិកាគណៈកម្មការពីររូប ក្នុងនោះបុគ្គលមួយរូបត្រូវជាសមាជិក ឬ សមាជិកានៃថ្នាក់ដឹកនាំ។

12.2 ប្រធានអាចធ្វើជាប្រធាននៃអង្គប្រជុំគណៈកម្មការប្រតិបត្តិ អង្គប្រជុំគណៈកម្មការ និងសន្និបាតប្រចាំឆ្នាំ លើកលែងតែអវត្តមានរបស់ប្រធាន ឬ តាមការស្នើរបស់ប្រធាន ឬ តាមមតិភាគច្រើនរបស់អង្គប្រជុំ អនុប្រធាន ឬ សមាជិក សមាជិកាណាម្នាក់អាចត្រូវបានចាត់តាំងជាប្រធាននៃអង្គប្រជុំនោះ។

12.3 ប្រធាននៃអង្គប្រជុំនីមួយៗ មានសិទ្ធិបោះឆ្នោតបញ្ចប់ការជាប់គាំង រួមជាមួយសិទ្ធិក្នុងការបោះឆ្នោតជាលើកទីពីរ (២) ប្រសិនជាលទ្ធផលនៃការបោះឆ្នោតស្មើគ្នា។

12.4 ប្រធានសមាគមត្រូវរៀបចំរបៀបវារៈសម្រាប់ការប្រជុំគណៈកម្មការ និងប្រជុំទូទៅដោយមានការពិគ្រោះយោបល់ជាមួយសមាជិក និងសមាជិកានៃគណៈកម្មការ។

12.5 ប្រធាននៃអង្គប្រជុំត្រូវលើកទឹកចិត្តឱ្យសមាជិកទាំងអស់ មានការចូលរួម បញ្ចេញមតិក្នុងអង្គប្រជុំហើយត្រូវចាត់ចែងរបៀបវារៈតាមលំដាប់លំដោយ។

12.6 ប្រធានត្រូវធ្វើជាអ្នកនាំពាក្យ លើកលែងតែគណៈកម្មការ ឬ អង្គប្រជុំទូទៅបានតែងតាំងអ្នកនាំពាក្យណាម្នាក់។ អ្នកនាំពាក្យត្រូវធ្វើសេចក្តីថ្លែងការណ៍តាមលក្ខខណ្ឌដែលបានចែងរួចស្រេច ឬ នៅពេលចាំបាច់បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយសមាជិក និងសមាជិកាគណៈកម្មការយ៉ាងតិចពីរ (២) រូប។

12.7 បុគ្គលមួយរូបអាចធ្វើជាប្រធានបានរយៈពីរ (២) អាណត្តិជាប់គ្នាតែប៉ុណ្ណោះ។

**មាត្រា ១៣ - ហេរញ្ញិក**

13.1 ហេរញ្ញិកត្រូវតែដាក់បញ្ចូលថវិកាដែលបានទទួលទាំងអស់ ទៅក្នុងគណនេយ្យរបស់សមាគមតាមការសម្រេចរបស់គណៈកម្មការ។ នៅពេលការចំណាយត្រូវចាយជាក្រដាសប្រាក់ដោយសាច់ប្រាក់តិចតួច ឬ ចាយជាសែក (Cheque) ត្រូវមានហត្ថលេខាពីរ (២) ដែលបានតែងតាំងក្នុងចំណោមហត្ថលេខីមិនលើសពីប្រាំ (៥) រូបពីសមាជិក និងសមាជិកាគណៈកម្មការ។

13.2 ការចំណាយធំៗ ឬ ការចំណាយមិនប្រក្រតីដែលមានចំនួនតិចជាងប្រាំពាន់ដុល្លារ ($៥០០០) ត្រូវមានការអនុញ្ញាតជាមុនពីគណៈកម្មការ។

13.3 ការចំណាយធំៗ ឬ ការចំណាយមិនប្រក្រតីដែលមានចំនួនត្រឹម ឬ ច្រើនជាងប្រាំពាន់ដុល្លា រ($៥០០០) ត្រូវតែមានការសម្រេចជាមុនសិនពីអង្គប្រជុំពិសេស ដោយមានការអនុម័តយ៉ាងតិចណាស់ពីរភាគបី (២/៣) នៃ

វត្តមានរបស់អង្គប្រជុំនោះ។

13.4 ហេរញ្ញិកត្រូវរក្សាទុកនូវកំណត់ត្រាចំណូល និងចំណាយទាំងអស់ និងកិច្ចការចំណាយដទៃទៀត។ សមាជិក និងសមាជិកាទាំងអស់មានសិទ្ធិសុំពិនិត្យកំណត់ត្រាហិរញ្ញវត្ថុទាំងអស់នោះ។

13.5 ហេរញ្ញិកត្រូវធានារៀបចំផែនការហិរញ្ញវត្ថុ និងរបាយការណ៍ ហើយត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុនោះទៅគណៈកម្មការដើម្បីពិនិត្យយ៉ាងតិចណាបី (៣) ខែម្តង។

13.6 ហេរញ្ញិកត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយរួមទាំងគណនីចំណូល និងចំណាយ របាយការណ៍ទ្រព្យសម្បត្តិ និងបំណុល ឬ ធ្វើរបាយការណ៍គណនីនៃប្រាក់ចំណូល និងការចំណាយ និងតារាងតុល្យការមួយនៅពេលដំណាច់ឆ្នាំ ដែលត្រូវចាប់ផ្តើមនៅថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា លើកលែងតែមានការកែប្រែក្នុងអង្គប្រជុំសាមញ្ញណាមួយ។

13.7 ហេរញ្ញិកត្រូវប្រាកដថា របាយការណ៍ថវិការប្រចាំឆ្នាំត្រូវបានពិនិត្យធ្វើសវនកម្មរួចហើយមុននឹងបង្ហាញទៅអង្គសន្និបាតប្រចាំឆ្នាំ ដោយអ្នកធ្វើសវនកម្មឯករាជដែលត្រូវបានជ្រើសតាំងដោយគណកម្មការ។ ល្តឹកណាប្រសិនជាមានការផ្លាស់ប្តូរធ្វើសវនកម្មនោះ ហេរញ្ញិកត្រូវរាយការណ៍ពីការផ្លាស់ប្តូរនោះ នៅក្នុងរបាយការណ៍ថវិការដល់អង្គសន្និបាតប្រចាំឆ្នាំ។

## មាត្រា ១៤ - លេខាធិការ

14.1 លេខាធិការត្រូវតែជូនដំណឹងអំពីការប្រជុំ យោងតាមបទបញ្ញត្តិរបស់លក្ខន្តិកៈនេះ។

14.2 លេខាធិការត្រូវតែរក្សាកំណត់ត្រារបស់សមាគមរួមទាំង ៖

- លក្ខន្តិកៈ និងគោលការណ៍
- បញ្ជីសមាជិកភាព
- បញ្ជីកំណត់ហេតុប្រជុំ និងលិខិតជូនដំណឹង
- សំណុំលិខិតឆ្លើយឆ្លងនានា
- កំណត់ត្រាការដាក់ស្នើផ្សេងៗ ឬ
- របាយការណ៍ ឯកសារផ្សេងៗដែលសមាគមបានធ្វើឡើងក្នុងនាមជាសមាគម។

14.3 នៅពេលដែលមានអវត្តមានរបស់លេខាធិការ ឬ មានការស្នើសុំពីលេខាធិការ ឬ ក៏មានការស្នើសុំភាគច្រើនពីអង្គប្រជុំនោះ សមាជិក ឬ សមាជិកាម្នាក់ទៀតអាចតែងតាំងបានឱ្យធ្វើជាលេខាធិការកត់ត្រាកំណត់ហេតុអង្គប្រជុំ។

## មាត្រា ១៥. - បុគ្គលិក

15.1 បុគ្គលិកដែលបានទទួលប្រាក់ខែពីសមាគម និងអ្នកស្ម័គ្រចិត្តទាំងអស់ត្រូវគោរពតាមគោលការណ៍ និងនីតិវិធីនៃកន្លែងធ្វើការរបស់សមាគម។

15.2 បុគ្គលិកធ្វើការឱ្យសមាគមអាចជាសមាជិក សមាជិកាសមាគម ឬ ជាសមាជិក សមាជិកាអនុគណៈកម្មការណាមួយបាន។

15.3 បុគ្គលិកដែលបានទទួលប្រាក់ខែជាទៀងទាត់ពីសមាគមអាចជាសមាជិក សមាជិការបស់គណៈកម្មការបាន ប៉ុន្តែមិនត្រូវចូលរួមធ្វើការសម្រេចចិត្តក្នុងកិច្ចការបង់ប្រាក់ឡើយ។ សមាជិក និងសមាជិការបស់សមាគមមានសិទ្ធិស្នើឱ្យមានអវត្តមានក្នុងការសម្រេចចិត្តនានាទៅលើកិច្ចការទាក់ទងនឹងបុគ្គលិកប្រសិនជាមានការស្នើសុំភាគច្រើនពីសមាជិក សមាជិកាគណៈកម្មការ។

**មាត្រា ១៦ - កំណែទម្រង់លក្ខន្តិកៈ និងវិន័យ**

16.1 លក្ខន្តិកៈនេះអាចលុប ឬ កែបានដោយការសម្រេចពីសេចក្តីសម្រេចចិត្ត ដែលមានសម្លេងបីភាគបួននៃសមាជិក សមាជិកា និងការបោះឆ្នោតនៅពេលប្រជុំសាមញ្ញចេញពីសមាជិកដែលមានវត្តមានពីរភាគបី (២/៣) និងការបោះឆ្នោតនៅពេលប្រជុំសាមញ្ញមួយ។ ការប្រកាសប្រាប់ទៅសមាជិក សមាជិកាសមាគមត្រូវធ្វើក្នុងរយៈពេលយ៉ាងតិចដប់បួន (១៤) ថ្ងៃ ស្តីអំពីសំណើលុប ឬ កែលក្ខន្តិកៈនេះនៅពេលប្រជុំសាមញ្ញ។ កម្មវត្ថុនៃសំណើនោះត្រូវតែពន្យល់ប្រាប់នៅអង្គប្រជុំសាមញ្ញ និងមុនអង្គប្រជុំតាមសំណើរពីសមាជិក សមាជិកាណាមួយ។

16.2 វិន័យសម្រាប់ការចាត់ចែងនៃអង្គប្រជុំនានា ឬ កិច្ចការសមាគមនានា អាចរៀបធ្វើឡើង, អាចលុបចោល ឬ អាចកែបានដោយអង្គប្រជុំសាមញ្ញមួយ ឬ ដោយការប្រជុំរបស់គណៈកម្មការដោយយោងទៅលើការមិនយល់ព្រមជាបន្តបន្ទាប់នៅអង្គប្រជុំសាមញ្ញណាមួយ។ ការរៀបចំវិន័យទាំងនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ (រួមទាំងដំណឹងពីសំណើវិន័យថ្មី ការកែប្រែ ឬ លុបចោលទាំងឡាយ) ផ្ញើជូនទៅសមាជិក សមាជិកាទាំងអស់យ៉ាងតិចណាស់ដប់បួន (១៤) ថ្ងៃមុននឹងអង្គប្រជុំសាមញ្ញនោះ។

**មាត្រា ១៧ - ការទទួលខុសត្រូវ ទ្រព្យសម្បត្តិ និងការរំលាយ**

17.1 បុគ្គលដែលមានមានសិទ្ធិអំណាចនៅក្នុងគណៈកម្មការ ហើយបានរងនូវបំណុលណាមួយ ឬ រងការទទួលខុសត្រូវក្នុងបុព្វហេតុកិច្ចការបម្រើសមាគម បុគ្គលនោះនឹងត្រូវបានសមាគមទទួលខុសត្រូវសំណងជំនួសដោយមិនឱ្យបុគ្គលនោះត្រូវខាតបង់ផ្ទាល់ខ្លួនឡើយ។

17.2 ទ្រព្យចំណូល និងថវិការរបស់សមាគមត្រូវប្រើសម្រាប់តែពង្រីកគោលការណ៍ និងបម្រើកិច្ចការសមាគមប៉ុណ្ណោះ និង មិនត្រូវចំណាយ ឬ ផ្ទេរបង្វែរទៅឱ្យសមាជិក សមាជិកា ឬ ញាតិសន្តានរបស់សមាជិក សមាជិកាណាមួយឡើយ លើកលែងណាការបង់ប្រាក់ដល់បុគ្គលទាំងឡាយនោះបានជួយដល់កិច្ចការបម្រើ ឬ ជួយពង្រីកគោលការណ៍សមាគម ឬ បុគ្គលទាំងឡាយនោះបានធ្វើឱ្យសមាគមមានការជឿនលឿនដោយផ្អែកទៅលើគោលការណ៍របស់សមាគម និងមិនជ្រុលហួសហេតុ។

17.3 សមាគមមិនត្រូវរំលាយ លើកលែងតែមានការយល់ព្រមមិនតិចជាសម្លេងបីភាគបួន (៣/៤) នៃសមាជិក សមាជិកាដែលបានចូលរួម និងបោះឆ្នោតនៅអង្គប្រជុំដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងនោះ។ មិនតិចជាងមួយ (១) ខែ ការជូនដំណឹង និងគោលបំណងនៃការរំលាយទាំងនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់សមាជិក សមាជិកាទាំងអស់របស់សមាគម។

17.4 ប្រសិនជាសមាគមនេះត្រូវបានរំលាយ ឬ ការយល់ព្រមលើកលែងប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលត្រូវបានរំលាយ (មួយណាដែលកើតឡើងមុន), អ្វីដែលលើសពីសេចក្តីត្រូវការដូចបានរៀបរាប់ដូចខាងក្រោមនឹងត្រូវផ្ទេរទៅឱ្យអង្គការផ្សេងៗដែលមានគោលការណ៍ស្រដៀងគ្នានឹងសមាគមដែលជាអង្គការមនុស្សធម៌ដោយយោងទៅតាមច្បាប់៖

a. កាដូរជាទឹកប្រាក់ ឬ ទ្រព្យសម្បត្តិដែលទាក់ទងទៅនឹងគោលបំណងចំបងរបស់សមាគម

b. ការជួយឧបត្ថម្ភដែលទាក់ទងទៅនឹងការរៃអង្គាសប្រាក់ដែលបានធ្វើនៅកម្មវិធីណាមួយដែលទាក់ទងទៅនឹងគោលបំណងចំបងរបស់សមាគម

c. ថវិការដែលទទួលបានពីអង្គការនានាដូចជាកាដូរ និងការជួយឧបត្ថម្ភនានា។